# ពេលវេលាដ៏អស្ចារ្យនៃជំនឿគ្រិស្តបរិស័ទកំពុងតែកើតឡើងក្នុងប្រទេសកម្ពុជា

របៀបដែលប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍មួយនេះបានប្រែក្លាយពីប្រទេសដែលមានក្រុមជំនុំលាក់កំបាំងទៅជាមានការរីកចម្រើននៅលើការដាំក្រុមជំនុំវិញ។

**រៀបរៀងដោយ Kate Shellnutt ពីរាជធានីភ្នំពេញ**
**រូបថតដោយ Claire Eggers**

គ្រូគង្វាលរាប់ពាន់នាក់បានប្រមូលផ្តុំគ្នាយ៉ាងច្រើនកកកុញនៅជុំវិញលោកនាយករដ្ឋមន្ត្រីហ៊ុនសែន ដោយលើកទូរស័ព្ទស្មានហ្វូន និងថតរូបសែលហ្វីដើម្បីជាការរំឭកពីជំនួបដំបូងបង្អស់របស់លោកជាមួយគ្រិស្តបរិស័ទក្នុងប្រទេស។

ជំនួបដែលរៀបចំដោយរាជរដ្ឋាភិបាល ក្នុងការជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំក្រុមជំនុំជាង ២៥០០ នាក់កាលពីខែមិថុនាឆ្នាំមុន ជាកាយវិការដ៏សំខាន់ដែលត្រូវបានបង្ហាញឡើងនៅក្នុងប្រទេសដែលកាន់ព្រះពុទ្ធសាសនា ហើយធ្លាប់មានគ្រិស្តបរិស័ទត្រូវគេសម្លាប់ដោយសារជំនឿ និងបង្ខិតបង្ខំឲ្យលាក់ខ្លួនកាលពីពីរបីទសវត្សរ៍មុន។

លោក ទេព សំណាង នាយកប្រតិបត្តិនៃ ប្រិយសម្ពន្ធគ្រីស្ទបរិស័ទកម្ពុជា (EFC) ដែលជាបណ្តាញក្រុមជំនុំអន្តរនិកាយតំណាងឲ្យគ្រិស្តបរិស័ទភាគច្រើននៅក្នុងប្រទេសមានប្រសាសន៍ថា ជំនួបជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន «ជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែលមិនធ្លាប់កើតឡើងពីមុនមក។ នេះជាសញ្ញាដែលបង្ហាញថា (រាជរដ្ឋាភិបាល) កាន់តែទទួលស្គាល់ពីសហគមន៍គ្រិស្តបរិស័ទជាសាធារណៈ។»

នៅខណៈពេលដែលការបៀតបៀននៅតែកើតឡើងក្នុងប្រទេសដទៃទៀតនៅតំបន់អាស៊ីអាគ្នេយ៍ គ្រិស្តបរិស័ទនៅប្រទេសកម្ពុជាកំពុងតែទទួលបាននូវការបើកចំហពីថ្នាក់ដឹកនាំ និងអ្នកជិតខាង ដែលជាជោគជ័យមួយ។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រាប់ទៅកាន់គ្រូគង្វាលដែលជួបជុំនៅឯសាលបុរីកោះពេជ្រដ៏ប្រណីត ជាតំបន់ដែលមានការអភិវឌ្ឍយ៉ាងឆាប់រហ័សនាកណ្តាលរាជធានីភ្នំពេញថា «អ្នករាល់គ្នាមានសុខសន្តិភាពហើយ។ ខ្ញុំក៏ទទូចដល់សាសនាទាំងអស់នៅក្នុងប្រទេសកម្ពុជាមិនឲ្យប្រមាថអ្នករាល់គ្នា ឬនិកាយរបស់អ្នករាល់គ្នាដែរ។» ទោះបីជាគ្រិស្តបរិស័ទមិនត្រូវបានអនុញ្ញាតឲ្យអធិស្ឋាន ឬថ្លែងចំណាប់អារម្មណ៍ លោក សំណាង បន្តថា «យ៉ាងហោចណាស់ នេះជាផ្កាភ្លើងដើម្បីបន្តឲ្យភ្លើងឆាបឆេះ។»

ទោះបីជាគ្រិស្តបរិស័ទមានចំនួនត្រឹម ២.៥ ភាគរយនៅក្នុងចំណោមប្រជាជនជាង ១៦ លាននាក់ក្តី ក៏ចំនួននេះបន្តកើនឡើងនៅក្នុងប្រទេសដែលធ្លាប់ត្រូវបានគ្រប់គ្រងដោយរបបកុម្មុយនីស្ត និងមានវត្តអារ៉ាមដំបូលពណ៌មាសច្រើនកុះករ ទាំងនៅទីក្រុងដែលមានអគារខ្ពស់ស្កឹមស្កៃ និងជនបទដាច់ស្រយាល។ វត្តអារ៉ាមជាទីកន្លែងជួបជុំសម្រាប់ពុទ្ធសាសនិកខ្មែររាប់លាននាក់ មកប្រារព្ធពិធីបុណ្យតាមព្រះពុទ្ធសាសនារៀងរាល់ឆ្នាំៗ។

ប៉ុន្តែ នៅពេលនេះប្រទេសកម្ពុជាមានអ្នកដឹកនាំជំនាន់មួយដែលទទួលការបណ្តុះបណ្តាល និងសិទ្ធិសេរីភាពក្នុងការផ្សាយដំណឹងល្អនៅទូទាំងប្រទេស ហើយអ្នកជឿដែលមានចិត្តក្លាហានកំពុងក្តាប់យកឱកាសនេះ៖

- អង្គការសម្ព័ន្ធបេសកកម្មគ្រីស្ទាន (CMA) ជានិកាយគ្រិស្តបរិស័ទដែលបានដំណើរការយូរជាងគេ និងល្បីល្បាញជាងគេនៅក្នុងប្រទេស ធ្វើការប៉ាន់ប្រមាណថា គ្រិស្តបរិស័ទខ្មែរបានកើនឡើងច្រើនជាងពាក់កណ្តាលចាប់ពីឆ្នាំ ២០១០ ហើយនៅពេលនេះ អ្នកជឿមានប្រមាណជា ៣00000 នាក់។

- ប្រិយសម្ពន្ធគ្រីស្ទបរិស័ទកម្ពុជាបានចាប់ផ្តើម បេសកកម្មកម្ពុជា ២០២១, ដែលជាការផ្តួចផ្តើមក្នុងការដាំក្រុមជំនុំមួយនៅតាមភូមិនីមួយៗ។

- នៅក្នុងពេលជាមួយគ្នានេះ សម្ព័ន្ធក្រុមជំនុំជីវិតថ្មី ជាចលនាមួយដែលកំពុងតែរីកចម្រើនចេញពីក្រុមជំនុំដ៏ធំមួយនៅក្នុងទីក្រុងភ្នំពេញ មានផែនការក្នុងការចាប់ផ្តើមដាំក្រុមជំនុំ និងក្រុមកោសិកាចំនួន ៥00។ មកទល់សព្វថ្ងៃ ចលនានេះបានដាំក្រុមជំនុំជាង ២00 នៅក្នុងខេត្តចំនួន ១៣ នៃខេត្តចំនួន ២៤។

លោក នាក់ ផាន់ណា គ្រូបង្រៀនភាសាអង់គ្លេសវ័យ ៣២ ឆ្នាំ ដែលស្ថិតនៅក្នុងចំណោមក្រុមសិស្សដែលបានទទួលជឿតាមរយៈក្រុមជំនុំជីវិតថ្មីដែលមានសមាជិកជាង ២000 នាក់ ចាប់តាំងពីដើមសហស្សវត្សរ៍ថ្មីមានប្រសាសន៍ថា «នេះជាពេលវេលាដ៏បើកចំហ ហើយយើងមិនដឹងថាពេលវេលានេះនឹងបន្តយូរប៉ុណ្ណាទៀតទេ។ នេះជាពេលវេលានៃឱកាសដ៏សំខាន់... យើងឃើញថាគ្រិស្តបរិស័ទកំពុងនាំការផ្លាស់ប្តូរ។ ព្រះជាម្ចាស់កំពុងតែធ្វើកិច្ចការដែលយើងអាននៅក្នុងព្រះគម្ពីរ។»

អ្នកដឹកនាំនៅតាមនិកាយផ្សេងៗតែងពោលមកកាន់ទស្សនាវដ្តី *Christianity Today* កាលពីយើងបានធ្វើដំណើរទៅនាខែកញ្ញាឆ្នាំមុនថា នេះជាពេលវេលាដែលត្រូវរៀបចំផែនការធំ និងមានការអធិស្ឋានច្រើន។

ពួកគេចង់ឃើញគ្រិស្តបរិស័ទកើនចំនួនដល់ ១០ ភាគរយ ដោយកើនឡើង «តាមរបៀបដូចគ្នាដែលព្រះជាម្ចាស់បានផ្លាស់ប្រែប្រទេសកូរ៉េខាងត្បូង» ជាប្រសាសន៍របស់លោក សែម សុភា គ្រូគង្វាលនៃសាខាក្រុមជំនុំជីវិតថ្មី នៅជាយក្រុងភ្នំពេញ។ នៅខណៈពេលដែលរាជធានីភ្នំពេញត្រូវបានពង្រីក លោកសុភាបានឃើញក្រុមជំនុំដែលលោកបានដាំបានរីកចម្រើនពីសមាជិក ២៥នាក់មកជាង ៣00 នាក់នាពេលសព្វថ្ងៃ។

បេសកជនអាមេរិកម្នាក់មានប្រសាសន៍ថា ការជួបជុំជាមួយមនុស្សប៉ុន្មានរយនាក់នៅក្រុមជំនុំនាព្រឹកថ្ងៃអាទិត្យ គឺ «ដូចជាក្រុមជំនុំ Saddleback នៅប្រទេសកម្ពុជាអញ្ចឹង។» នៅទីនេះ ប្រជាជនជាង ៨0ភាគរយរស់នៅតាមទីជនបទ ហើយក្រុមជំនុំគ្រិស្តបរិស័ទអាចជាក្រុមជំនុំជួបជុំតាមផ្ទះតូចៗប៉ុណ្ណោះ។

## ជំនឿយ៉ាងមោះមុតបន្ទាប់ពីបានឆ្លងកាត់ភ្លើងសង្គ្រាម

នៅឯ មហាសន្និបាតគ្រិស្តបរិស័ទអាស៊ី រាជធានីភ្នំពេញ ដែលត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំ តន្ត្រីថ្វាយបង្គំជាភាសាខ្មែរត្រូវបានប្រគុំយ៉ាងឮរំពង អមដោយភ្លៀងរដូវវស្សាដែលបង្អុរចុះមកយ៉ាងជោកជាំនៅលើកោស៊ូតង់ពណ៌ក្រហមលាយ-ស ខាងក្រៅអគារមជ្ឈមណ្ឌលសន្និបាតដែលមានមនុស្សច្រើនកុះករ។ មានយុវជនស្លៀកខោរឹប និងពាក់ជ័រនតាជងក្រាស់ៗស្រែកច្រៀងថា «ខ្ញុំលើកដៃឡើង ទាំងស្ញប់ស្ញែងព្រះអង្គ» នៅខណៈដែលភ្លើងហ្វាបញ្ចាំងពីលើឆាកមក។

លោក Jesse McCaul គ្រូគង្វាលរៀមច្បងនៃក្រុមជំនុំជីវិតថ្មីមានប្រសាសន៍ថា សន្និបាតនេះជាព្រឹត្តិការណ៍គ្រិស្តបរិស័ទដែលធំបំផុតនៅក្នុងប្រទេសកម្ពុជា។ លោក Chuck ដែលជាឪពុករបស់លោកបានចាប់ផ្តើមក្រុមជំនុំនេះនៅឆ្នាំ ១៩៩៤ គឺភ្លាមៗនៅពេលដែលបេសកជនបរទេសត្រូវបានអនុញ្ញាតឲ្យត្រឡប់មកប្រទេសនេះវិញ។ ព្រឹត្តិការណ៍ប្រចាំឆ្នាំ ២០១៦ នេះ មានមនុស្សជាង ៤៥០០ នាក់ចូលរួម ហើយត្រូវការអ្នកស្ម័គ្រចិត្តជាយុវសិស្សជាង ៥៥០ នាក់ពីក្រុមជំនុំ។

ដូចជាវិស័យផ្សេងៗនៅក្នុងប្រទេសកម្ពុជា គ្រិស្តសាសនានៅមានភាពក្មេងខ្ចីនៅឡើយ។ បន្ទាប់ពីបានឆ្លងកាត់ភ្លើងសង្គ្រាមស៊ីវិល និងអំពើប្រល័យពូជសាសន៍ ជាក់ស្តែងដូចជាអ្វីដែលបានកើតឡើងនៅក្នុងភាពយន្តឯកសារ វាលពិឃាដ ជាភាពយន្តដ៏ល្បីរន្ទឺ និងគួរឲ្យតក់ស្លុត ប្រជាជន ៦០ភាគរយនៅក្នុងចំណោមប្រជាជនទូទាំងប្រទេសគឺស្ថិតក្រោមអាយុ ៣០ ឆ្នាំ។ មានគ្រិស្តបរិស័ទតែបន្តិចប៉ុណ្ណោះដែលអាចនិយាយពីពេលដែលពួកគេចាប់ផ្តើមទទួលជឿលើព្រះយេស៊ូ មុនពេលដែលប៉ុលពត និងរបបខ្មែរក្រហមបានកាន់កាប់ប្រទេសនៅឆ្នាំ ១៩៧៥។

ក្រុមបេសកជនគ្រិស្តបរិស័ទប្រតេស្តង់ដំបូងគេដែលបានមកប្រទេសកម្ពុជានៅឆ្នាំ ១៩២៣ គឺមកជាមួយអង្គការ CMA។ ពួកគេបានបណ្តុះបណ្តាលគ្រូគង្វាលក្នុងតំបន់ បកប្រែព្រះគម្ពីរ និងរៀបចំជាព័ន្ធកិច្ចនៅតាមភូមិអស់រយៈពេលជាច្រើនទសវត្សរ៍។ ប៉ុន្តែ ទើបតែនៅសម័យសង្គ្រាមវៀតណាមដែលកើតឡើងឥតស្រាកស្រាន្ត ក្រុមជំនុំបានឃើញនូវការរីកចម្រើនគួរឲ្យកត់សម្គាល់ គឺកើនឡើងពីអ្នកជឿជាង ១០០០ នាក់ ទៅដល់ជាង ១០០០០ នាក់នៅចន្លោះឆ្នាំ ១៩៧០ និង ១៩៧៥។ បន្ទាប់មក របបខ្មែរក្រហមកុម្មុយនីស្តដ៏ឃោរឃៅក៏បានចូលមកដល់។

មានគេនិយាយថា មានក្រុមជំនុំមួយនៅឯទីក្រុងភ្នំពេញបានប្រមូលផ្តុំគ្រិស្តបរិស័ទជាង ៦០០ នាក់មកជួបជុំអធិស្ឋានមុនពេលបដិវត្តន៍បានកើតឡើងត្រឹមប៉ុន្មានសប្តាហ៍ប៉ុណ្ណោះ។ សមាជិកទាំងនោះបានសន្យាថានឹងត្រឡប់ទៅកាន់ក្រុមជំនុំវិញ ហើយចារឈ្មោះរបស់ពួកគេនៅលើជញ្ជាំងដើម្បីឲ្យគ្រប់គ្នាដឹងថាពួកគេបានរួចជីវិត។ ប៉ុន្មានឆ្នាំក្រោយមក មានឈ្មោះតែបីប៉ុណ្ណោះដែលត្រូវបានចារនៅលើជញ្ជាំង។ នៅចុងឆ្នាំ ១៩៧៩ គេជឿថាមានគ្រិស្តបរិស័ទត្រឹមជាង ២០០ នាក់ប៉ុណ្ណោះដែលនៅមានជីវិតក្នុងប្រទេស។

ដូច្នេះ អង្គការគ្រិស្តបរិស័ទដែលមានវត្តមានក្នុងប្រទេសកម្ពុជាដូចជាអង្គការ CMA និងទស្សនៈពិភពលោក បានប្តូរព័ន្ធកិច្ចរបស់ពួកគេមកផ្តោតលើជំរំជនភៀសខ្លួននៅតាមជាយដែន ជាកន្លែងដែលក្រុមជំនុំបន្តបន្ថែមអ្នកជឿថ្មីថែមទៀត។ មានជំរំមួយចំនួនមានអ្នកចូលរួមថ្វាយបង្គំជាង ១០០០០ នាក់ជួបជុំគ្នារាល់សប្តាហ៍។ អ្នកដឹកនាំគ្រិស្តបរិស័ទវ័យចំណាស់ជាច្រើននាក់ បានទទួលជឿកាលដែលពួកគាត់នៅក្នុងជំរំជនភៀសខ្លួន។

គ្រិស្តបរិស័ទវ័យចំណាស់ជាងគេដែល CT បានជួបគឺលោកយាយ បុត្រ បុប្ផា ដែលមានអាយុ ៧០ ឆ្នាំ ហើយដែលបានក្លាយជាគ្រិស្តបរិស័ទនៅអាយុ ៨ ឆ្នាំ។ លោកយាយបុប្ផាបានយកកូនព្រះគម្ពីរមកជាមួយ ពេលដែលលោកយាយមកជំរំសាយធូ ដែលជាជំរំធំជាងគេសម្រាប់ជនភៀសខ្លួនកម្ពុជាក្នុងទឹកដីថៃជាប់នឹងព្រំដែនកម្ពុជា។ ទាំងមានវ័យចំណាស់ និងបាត់បង់ធ្មេញអស់រលីង លោកយាយមានប្រសាសន៍ប្រាប់ CT ថា «ខ្ញុំបានជួបនឹងគ្រូគង្វាលម្នាក់ ហើយខ្ញុំបានរៀនកាន់តែច្រើនអំពីព្រះជាម្ចាស់។ នៅពេលដែលខ្ញុំទើបតែត្រឡប់មកវិញ កាលនោះយើងជាក្រុមជំនុំជួបគ្នាស្ងាត់ៗ។ យើងចាំបាច់ត្រូវជួបគ្នានៅកន្លែងស្ងាត់។»

លោក គង់ យ៉ូសែប បានលាលែងពីការងារជាមន្ត្រីរដ្ឋបាលព្រៃឈើនៅពេលមួយខែ មុនដែលបដិវត្តន៍បានកើតឡើង។ លោកបានទៅដល់ជំរំស្នាក់នៅថ្មីឯរដ្ឋអូរីហ្គិន ដែលនៅទីនោះលោកបានជួយក្រុមជំនុំ CMA ដែលនិយាយភាសាខ្មែរនៅតំបន់ប៉ាស៊ីហ្វិកភាគពាយព្យឲ្យរីកចម្រើនឡើង។

លោកជាម្នាក់ក្នុងចំណោមក្រុមបេសកជនកម្ពុជាដំបូងដែលបានត្រឡប់មកប្រទេសកម្ពុជាវិញ នៅពេលដែលប្រទេសនេះបើកចំហសម្រាប់សកម្មភាពសាសនាឡើងវិញនៅដើមឆ្នាំ ១៩៩០។ រាប់ចាប់តាំងពីព្រឹត្តិការណ៍ផ្សាយដំណឹងល្អខ្នាតធំនៅតាមរោងមហោស្រពរដ្ឋដែលមានមនុស្សចូលរួមច្រើនកុះករឯទីក្រុងភ្នំពេញ រហូតដល់ការដើរពីផ្ទះមួយទៅផ្ទះមួយនៅតាមភូមិ ក្រុមការងាររបស់លោកបានបន្ថែមអ្នកជឿថ្មីមកជាង ៥០០ នាក់ទៀតនៅក្នុងពេលជាងបីសប្តាហ៍។

លោកយ៉ូសែប ដែលបានរួមចំណែកក្នុងការចាប់ផ្តើមព័ន្ធកិច្ចមុន EFC បានចាប់បដិសណ្ឋិឡើង ហើយនៅបន្តជាប្រធានក្រុមគណៈនាយកនៃព័ន្ធកិច្ចនេះមានប្រសាសន៍ថា «ខ្ញុំចង់ថ្វាយជីវិតរបស់ខ្ញុំដាច់ដល់ព្រះជាម្ចាស់ ព្រោះទ្រង់បានសង្គ្រោះជីវិតខ្ញុំពីវាលពិឃាដ ហើយទ្រង់បានសង្គ្រោះព្រលឹងខ្ញុំដោយដំណឹងល្អ»។

នៅពេលនេះ ដែលមានធនធានដោយអ្នកដឹកនាំកាន់តែច្រើនដែលមានគុណវុឌ្ឍិ សាលាព្រះគម្ពីរ និងកម្មវិធីបណ្តុះបណ្តាល ក្រុមជំនុំកម្ពុជានៅសតវត្សរ៍ទី ២១ កាន់តែមានស្វ័យភាព ជាមួយនឹងបេសកជនពីខាងក្រៅដែលបម្រើក្នុងនាទីជាអ្នកជួយគាំទ្រ ហើយផ្តោតខ្លាំងលើការជួយមនុស្សឲ្យក្លាយជាសាវក។ អ្នកដឹកនាំនៅសព្វថ្ងៃនេះ មានឱកាសដែលមិនមានកាលពី ៣០, ២០ ឬក៏ ១០ ឆ្នាំមុន នៅខណៈដែលគ្រូគង្វាលជាច្រើននាក់បានស្មោះត្រង់រងទុក្ខលំបាកដោយភ្លើងសង្គ្រាម និងការបៀតបៀនឥតឈប់ឈរ បើយោងតាមប្រសាសន៍របស់លោកសំណាង។

អ្នកដឹកនាំ EFC វ័យ ៤៥ ឆ្នាំរូបនេះបន្តថា «សូមមើលមនុស្សជំនាន់ថ្មីដែលកំពុងដុះពន្លកឡើង។ ពួកគេមានចិត្តឆេះឆួល ទទួលការបំពាក់បំប៉នបានល្អប្រសើរ ព្រមទាំងមានយុទ្ធសាស្ត្រច្បាស់លាស់។ អ្នកជំនាន់មុនប្រហែលជាមិនមានសមត្ថភាព និងទទួលការបណ្តុះបណ្តាលល្អប្រសើរ ប៉ុន្តែពួកលោកមានបទពិសោធន៍។ អ្នកជំនាន់ក្រោយត្រូវគោរពអ្នកជំនាន់មុន ហើយរៀនពីពួកលោក។ ប៉ុន្តែនៅក្នុងពេលជាមួយគ្នានេះ អ្នកជំនាន់មុនក៏មិនអាចដាក់ដែនកំណត់នៅលើពួកគេបានដែរ។»

ការផ្លាស់ប្តូរនេះ ដូចជាលោកម៉ូសេដែលហុចបន្តនូវទំនួលខុសត្រូវជាអ្នកដឹកនាំទៅកាន់លោកយ៉ូស្វេ បង្ហាញពីពេលវេលាដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្រ និងការរីកចម្រើននៃក្រុមជំនុំខ្មែរ។ គ្រូគង្វាលខ្មែរជំនាន់ទីមួយដែលបានធ្វើដំណើរយ៉ាងស្មោះត្រង់នៅក្នុងវាលរហោស្ថាន គឺបន្ទាប់ពីសម័យកាលដ៏ខ្មៅងងឹតនៃប្រទេសកម្ពុជា កំពុងតែមាននូវក្រុមអ្នកដឹកនាំថ្មីក្រោកឡើង។ ពួកគេមកជាមួយនឹងសញ្ញាបត្រពីសាកលវិទ្យាល័យ ព្រមទាំង

ទទួលការបណ្ដុះបណ្ដាលសម្បូរបែបជាង ដែលនាំឲ្យពួកគេត្រៀមខ្លួនបានកាន់តែប្រសើរក្នុងការពង្រឹង និងជួយនាំក្រុមជំនុំដែលមានអ្នកជឿថ្មីៗឲ្យរីកចម្រើនជាសារវ័ក។

លោកយ៉ូសែបដែលបម្រើការជាមួយអង្គការ CMA មានប្រសាសន៍ថា «អ្នកចាំបាច់ត្រូវបន្ទាបខ្លួន ដើម្បីធ្វើការរួមជាមួយគ្នាទៅវិញទៅមក ដើម្បីផ្ដល់អំណាចដល់អ្នកដឹកនាំក្មេងៗ និងទុកចិត្តលើពួកគេ។»

## ប្រែក្លាយពីអ្នកស្វែងរកអត្ថប្រយោជន៍ ទៅជាអ្នកស្វែងរកព្រះគ្រិស្ត

នៅដើមឆ្នាំ ២០០០ ជាធម្មតាយុវជនកម្ពុជាបានឮដំណឹងល្អតាមរយៈកម្មវិធីឈោងចាប់របស់ក្រុមជំនុំដូចជាកម្មវិធីកុមារ ថ្នាក់បង្រៀនកុំព្យូទ័រ ឬថ្នាក់ភាសាអង់គ្លេស។

លោក ហេង សុទ្ធថា ជាប្រធានផ្នែកដាំក្រុមជំនុំនៅក្រុមជំនុំជីវិតថ្មី មានប្រសាសន៍ថា «មនុស្សធ្លាប់គិតថា ក្រុមជំនុំជាអង្គការអភិវឌ្ឍន៍មួយ ព្រោះមនុស្សភាគច្រើនមកក្រុមជំនុំដើម្បីទទួលបានប្រយោជន៍អ្វីម្យ៉ាង។ នៅពេលនេះ ពួកគេបែរជាមកដើម្បីទទួលការអស្ចារ្យទៅវិញ។»

ក្រុមជំនុំខ្មែរមានពេញទៅដោយទីបន្ទាល់អំពីការផ្លាស់ប្រែខាងវិញ្ញាណ និងការផ្លាស់ប្រែដ៏អស្ចារ្យដទៃទៀតដូចជា ស្ត្រីពិការភ្នែកដែលត្រូវខំប្រឹងមើលសៀវភៅទំនុកសរសើររបស់នាងប្រឹមៗ ប៉ុន្តែអាចមើលឃើញច្បាស់វិញក្រោយពីមានបេសកជនអធិស្ឋានឲ្យនាង កម្មករសំណង់ដែលរួចជីវិតបន្ទាប់ពីត្រូវពស់ពិសចឹក ក្មេងខាត់ស្បែកជើងក្រីក្រក្លាយជានាយកសាលាភាសាអង់គ្លេស។

ក្រុមជំនុំភាគច្រើន ជាពិសេសនៅតាមភូមិនានានៅតែពឹងផ្អែកលើកម្មវិធីក្នុងការផ្សាយដំណឹងល្អ។ អ្នកស្រី ទៀង សៀងឡៃ ដែលបម្រើក្នុងព័ន្ធកិច្ចជាមួយលោក ធីម៉ូថេ ជាស្វាមី និងជាគ្រូគង្វាលប្រចាំព្រះវិហារព្រះគម្ពីរប្រែសបីធើរៀនសៀមរាបទី១ មានប្រសាសន៍ថា «យើងឈោងចាប់ដល់ឪពុកម្ដាយតាមរយៈសិស្ស។» ព័ន្ធកិច្ចរបស់ពួកគេលាតសន្ធឹងនៅលើក្រុមជំនុំតាមភូមិចំនួន ១០ នៅក្នុងខេត្តភាគពាយព្យដែលមានមោទកភាពអំពីប្រាសាទអង្គរវត្តដ៏ល្បីល្បាញ ជាប្រាសាទដែលសង់ឡើងនាសតវត្សរ៍ទី ១២ ដែលសង់ឡើងសម្រាប់ព្រហ្មញ្ញសាសនា ហើយផ្លាស់ប្ដូរសម្រាប់ព្រះពុទ្ធសាសនា ព្រមទាំងកំពុងរងការបាក់បែកដោយអន្លើនេះ។

រូបគំនូរប្រាសាទអង្គរវត្តនៅលើទង់ជាតិប្រទេសកម្ពុជា តែងជាការរំឭកអំពីឫសគល់នៃសាសនារបស់ប្រទេសនេះ។ ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ហើយគ្រិស្តសាសនាជាសាសនារបស់អឺរ៉ុប។ មិនថាមនុស្សមានទស្សនៈបែបនេះក្ដី ក៏អ្នកជិតខាងតែងកោតសរសើរអំពីសេវាគ្លីនិក ឬថ្នាក់រៀនដែលក្រុមជំនុំផ្ដល់ជូនជានិច្ច។ ប្រជាជនក្រីក្ររស់នៅដោយប្រាក់ពីរបីដុល្លារក្នុងមួយថ្ងៃ ហើយជាញឹកញាប់ពួកគេមិនអាចមានលទ្ធភាពទទួលការថែទាំផ្នែកសុខភាព ឬបង់ថ្លៃសាលារៀនដោយខ្លួនឯងឡើយ។

ក្រុមជំនុំណាហ្សារីនបារាយណ៍ នៅភូមិភាគកណ្ដាលនៃប្រទេសកម្ពុជា ទទួលក្មេងៗនៅក្នុងភូមិជារៀងរាល់ថ្ងៃ ហើយជួយឧបត្ថម្ភដល់គ្រួសារក្រីក្រជាង ៦ គ្រួសារ។ នៅពេលដែល CT បានចុះទៅ ម្ដាយៗជាអ្នកជិតខាងបានអង្គុយលើទោងយោល កំពុងតែមើលកូនៗរបស់ពួកគេរៀនអក្សរខ្មែរ តាមរយៈការអង្គុយជារង្វង់លេងហ្គេមក្នុងទីធ្លាសាលា និងហាត់របាំប្រពៃណីនៅឯក្រុមជំនុំ។ ស្ត្រីម្នាក់សារភាពតាមរយៈអ្នកបកប្រែថា «យើងជឿព្រះពុទ្ធទេ។ ប៉ុន្តែយើងសប្បាយចិត្តដែលកូនៗរបស់ពួកយើងបានមកទីនេះ។»

លោក សិន ព្រំ គ្រូគង្វាលប្រចាំក្រុមជំនុំបារាយណ៍ បានចាប់ផ្តើមអញ្ជើញអ្នកជិតខាងឲ្យមកផ្ទះរបស់គាត់កាលពីឆ្នាំ២០០៦ គឺរយៈពេលប៉ុន្មានខែបន្ទាប់ពីគាត់បានក្លាយជាគ្រិស្តបរិស័ទដោយការឮដំណឹងល្អតាមវិទ្យុ។ ជាមួយនឹងជំនួយពីអង្គការទស្សនៈពិភពលោកប្រទេសកម្ពុជានៅឆ្នាំ ២០១៣ ពួកគេបានសង់អគារឈើមួយខ្នងនៅខាងមុខផ្ទះដើម្បីធ្វើជាក្រុមជំនុំ ដោយធ្វើការតុបតែងនៅខាងក្នុង និងក្រៅអគារដោយចាបក្រដាសកម្រងផ្កាចំប៉ីដែលមានក្លិនក្រអូប និងគំនូររបស់កុមារ។ ក្រុមជំនុំដែលនៅជិតបំផុតគឺត្រឹម ៦ ម៉ែល៍ (១០គីឡូម៉ែត្រ) ប៉ុណ្ណោះ ហើយទោះជាយ៉ាងនេះក៏ដោយ ការធ្វើដំណើរអាចត្រូវចំណាយពេលដល់ទៅ ៤៥ នាទី ដោយសារផ្លូវដីមានភាពរលាក់ និងមានសត្វពាហនៈស្គមៗដើរតាមផ្លូវនោះដែរ។

អ្នកស្រី សៀងឡៃ ប្រធានព័ន្ធកិច្ចកុមារ និងការផ្សាយដំណឹងល្អនៅព្រះវិហារព្រះគម្ពីរប្រែសប៊ីធីរៀនសៀមរាបទី ១ មានប្រសាសន៍ថា «នៅពេលដែលក្រុមជំនុំអាចធ្វើកិច្ចការបែបនេះក្នុងសង្គម វាបង្កើតឲ្យមានទស្សនៈវិជ្ជមាន ហើយ (អ្នកជិតខាង) លែងខ្លាចគ្រិស្តបរិស័ទទៀតហើយ។ ពួកគេនឹងថា "ខ្ញុំមកទីនេះដើម្បីរៀនភាសាអង់គ្លេសប៉ុណ្ណោះ ហើយមិនចង់ស្គាល់ព្រះយេស៊ូទេ។" ប៉ុន្តែ ពួកគេក៏នឹងមកចូលរួមថ្នាក់ព្រះគម្ពីរថ្ងៃអាទិត្យ ហើយធ្លាក់ក្នុងអន្លង់ស្នេហ៍របស់ព្រះយេស៊ូ។» អ្នកស្រីដឹងថា ស្ថានភាពនោះមានលក្ខណៈយ៉ាងណា។ ក្នុងនាមជាសិស្សឆ្នើមនៅខេត្តព្រះសីហនុ ជាខេត្តមួយដែលមានឆ្នេរសមុទ្រខៀវស្រងាត់ ហើយត្រូវបានដាក់ឈ្មោះតាមអតីតព្រះមហាក្សត្រនៃប្រទេសកម្ពុជា អ្នកស្រីមានអារម្មណ៍ថាព្រះជាម្ចាស់កំពុងមានបន្ទូលមកកាន់អ្នកស្រីតាមរយៈបទគម្ពីរមួយដែលគេបានយកមកឲ្យអ្នកស្រីបកប្រែ គឺសាច់រឿងអំពីការស្លាប់របស់លោកឡាសារនៅយ៉ូហាន ជំពូក ១១។

បន្ទាប់ពីអ្នកស្រី សៀងឡៃ បានក្លាយជាគ្រិស្តបរិស័ទ ឪពុកម្តាយ និងបងប្អូនរបស់អ្នកស្រីដែលកាន់ព្រះពុទ្ធសាសនាបានបន្ទុះបង្អាប់ដល់អ្នកស្រីចំពោះការអធិស្ឋានមុនញ៉ាំអាហារ។ អ្នកស្រីបានលាក់សៀវភៅនៅក្នុងថង់ពណ៌ខ្មៅ នៅពេលដែលអ្នកស្រីទៅក្រុមជំនុំថ្ងៃអាទិត្យ ដោយប្រាប់ពួកគេថាអ្នកស្រីទៅរៀន។ អ្នកស្រីសៀងឡៃ បញ្ជាក់ថា «ខ្ញុំមិនបានកុហកទេ។ ខ្ញុំទៅរៀនព្រះបន្ទូល។»

ជំនឿថ្មីនេះបង្ខំឲ្យជនជាតិកម្ពុជាគិតឡើងវិញពីទំនាក់ទំនងរបស់ពួកគេ ហើយក្នុងករណីខ្លះ ពួកគេត្រូវជ្រើសរើសរវាងព្រះជាម្ចាស់ និងក្រុមគ្រួសារ។ មុនពេលដែលជនជាតិកម្ពុជាថ្វាយជីវិតដាច់ក្នុងការដើរតាមព្រះយេស៊ូ «ពួកគេតាំងចិត្តរួចជាស្រេចថា "ក្រុមគ្រួសាររបស់ខ្ញុំជាពុទ្ធសាសនិក ឪពុកម្តាយខ្ញុំជាពុទ្ធសាសនិក មិត្តភក្តិខ្ញុំក៏ជាពុទ្ធសាសនិក។ ពួកគេនឹងបៀតបៀនខ្ញុំ។» ជាប្រសាសន៍របស់លោកសុភា ដែលជាគ្រូគង្វាលនៅឯជាយក្រុងភ្នំពេញ។

ដោយព្រោះថាក្រុមគ្រួសារខ្មែរមានប្រពៃណីដែលផ្តោតលើការទៅវត្តអារ៉ាម និងការសែនព្រេនដូនតា អ្នកដែលចង់ក្លាយជាគ្រិស្តបរិស័ទនឹងតែងតែសួរថា តើខ្លួនអាចនៅបន្តធ្វើកិច្ចការតាមប្រពៃណីទាំងនោះទៀតបានដែរឬទេ។ ប្រសិនបើលោកសុភាប្រកែក ពួកគេអាចនឹងលែងចាប់អារម្មណ៍លើគ្រិស្តសាសនា។ ផ្ទុយទៅវិញ លោកណែនាំពួកគេឲ្យសិក្សាពីអត្ថបទគម្ពីរ ហើយមើលថាតើព្រះជាម្ចាស់មានបន្ទូលយ៉ាងណា។ លោកបន្តថា «គ្មាននរណាប្រាប់ខ្ញុំថា "មិនត្រូវថ្វាយបង្គំរូបសំណាក" ទេ។ គោលដៅសំខាន់គឺកសាងទំនាក់ទំនងជាមួយពួកគេ ហើយបង្រៀនពួកគេអំពីសេចក្តីពិតបន្តិចម្តងៗ។ នៅពេលដែលពួកគេស្គាល់ព្រះជាម្ចាស់ហើយ ពួកគេនឹងលែងថ្វាយបង្គំរូបសំណាកទាំងនោះដោយខ្លួនឯង។»

## ឱកាសដើម្បី «ស្តែងចេញយ៉ាងពិតប្រាកដ»

វិសាលភាពនៃគ្រិស្តសាសនានៅទូទាំងសកលលោក បានបណ្តាលឲ្យជនជាតិកម្ពុជាជាច្រើននាក់ចាត់ទុកថាជាការគំរាមកំហែងនៅលើវប្បធម៌ ហើយក៏បានទាក់ទាញមនុស្សច្រើនផ្សេងទៀតនៅលើពិភពលោកមកកាន់ព្រះសង្គ្រោះ រហូតដល់មានប្រទេសជាច្រើនប្រើប្រាស់ប្រតិទិនរបស់ពួកគេតាមកាលបរិច្ឆេទនៃព្រះជន្ម និងការសុគតរបស់ទ្រង់។ អ្នកដែលបានក្លាយជាគ្រិស្តបរិស័ទកត់សម្គាល់ឃើញថា គ្រិស្តសាសនាឆ្លើយនូវសំណួរដែលពុទ្ធសាសនាមិនអាចឆ្លើយបាន ដូចជា *តើនរណាបានបង្កើតពិភពលោក?* ហើយ *តើនរណាបង្កើតមនុស្ស?*

លោក អ៊ូ សាវ័ន្ត អតីតអ្នកដឹកនាំនៅអង្គការ Cru ដែលកំពុងតែបម្រើការជាមួយកម្មវិធីមើលថែទាំក្នុងមណ្ឌលកុមារកំព្រាគ្រិស្តបរិស័ទមួយហៅថា ក្តីសង្ឃឹមអាស៊ី មានប្រសាសន៍ថា «ខ្ញុំធ្លាប់គិតថា ព្រះពុទ្ធជាព្រះរបស់ខ្មែរ ហើយព្រះយេស៊ូជាព្រះរបស់អាមេរិកាំង។ ប៉ុន្តែ (ព្រះយេស៊ូ) ជាព្រះទូទាំងសកលលោក។ ទ្រង់បានសុគត ហើយរស់ឡើងវិញ។ តើព្រះពុទ្ធបានធ្វើអញ្ចឹងដែរទេ? អត់ទេ។»

មុនពេលទៅរៀននៅសាលាព្រះគម្ពីរ លោកសាវ័ន្តធ្លាប់ធ្វើជាកងទ័ពនៅវ័យកុមារ ជាជនភៀសខ្លួន និងជាលោកនេន។ បទពិសោធន៍ទាំងនេះបានជួយឲ្យលោកយល់ថាតើជនរួមជាតិខ្មែរដទៃទៀតមានគំនិតបែបណា លោកមានប្រសាសន៍ថា «វាងាយស្រួលឲ្យខ្ញុំចែកចាយដំណឹងល្អ និងជួយឲ្យពួកគេទទួលព្រះគ្រិស្តនៅពេលនេះ។»

នៅឯក្រុមជំនុំ ព្រះវិហារព្រះគុណខេត្តបាត់ដំបង ដែលជាទីក្រុងធំជាងគេទីបីក្នុងប្រទេសកម្ពុជា ប្រពៃណីស្រដៀងគ្នាពីក្រុមជំនុំលោកខាងលិចត្រូវបានច្របាច់បញ្ចូលជាមួយប្រពៃណីក្នុងតំបន់។ នៅក្រុមជំនុំនេះមានស្បែកជើងសង្រែកប្រឡាក់ដីត្រូវបានគរជាពំនូកនៅឯមាត់ទ្វារ ហើយខ្លះទៀតត្រូវក្មេងៗយកទៅលេង នៅខណៈពេលដែលមនុស្ស ៦០ នាក់ថ្វាយបង្គំដោយជើងទទេលើកម្រាលឥដ្ឋរលោង។ នៅពេលដែល «ចែករំលែកសេចក្តីសុខសាន្ត» អ្នកចូលរួមឱនទៅរកគ្នាទៅវិញទៅមក ដោយលើកដៃសំពះជម្រាបសួរគ្នា។ បទចម្រៀងថ្វាយបង្គំសម័យត្រូវបានប្រគុំលាន់រំពងចេញពីធុងបាស់ធំៗ ហើយមានបទទំនុកបរិសុទ្ធបែបប្រពៃណីខ្មែរត្រូវបានប្រគុំអមជាមួយនឹងហ្គីតាសូឡូ។

គ្រូគង្វាល លឹម ផាន់នី បានអធិប្បាយចេញពីគម្ពីរ ១យ៉ូហានជំពូក ៣ ដោយប្រាប់ពួកជំនុំរបស់លោកពីរបៀបដែលព្រះជាម្ចាស់បានយាងមកលើផែនដី ដើម្បីប្រទានអំណោយដល់ពួកគេជាជីវិតអស់កល្ប។ លោកផាន់នីបានឮពីមេរៀននេះជាលើកដំបូង កាលដែលលោកនៅឯជំរំជនភៀសខ្លួនដែលលោកបានរត់គេចពីរបបខ្មែរក្រហម។ ដំណឹងល្អដែលបានជួយសង្គ្រោះលោក ក៏នៅតែជាដំណឹងល្អសម្រាប់ប្រជាជនកម្ពុជាដែរ។

លោកផាន់នី ដែលបានចាប់ផ្តើមក្រុមជំនុំកាលពីជាង ២៥ ឆ្នាំមុនមានប្រសាសន៍ថា «សម្រាប់ប្រជាជននៅទីនេះ ជីវិតរបស់ពួកគេមានភាពពិបាកណាស់។ ពិបាកធ្វើការ ពិបាកធ្វើស្រែចម្ការ ពិបាករកស៊ី។ យើងចំណាយពេលមួយថ្ងៃជុំគ្នាជាមួយក្រុមគ្រួសារយើង ហើយសិក្សាព្រះគម្ពីរ។ បន្ទាប់មក ខ្ញុំបញ្ជូនសិស្សទាំងនោះឲ្យទៅធ្វើការវិញ។»

សម្ពាធពីសង្គម និងសេដ្ឋកិច្ចនៃជីវិតនៅក្នុងប្រទេសកម្ពុជាអាចបង្កជាការលំបាកដល់កិច្ចការផ្សាយដំណឹងល្អ។ នៅឯក្រុមជំនុំបាទីស្ទតូចមួយឯខេត្តកំពង់ធំ ស្រ្តីវ័យជំទង់ម្នាក់ចែករំលែកពីទីបន្ទាល់របស់នាងជាមួយនឹងទឹកភ្នែករលីងរលោង។ នៅពេលដែលនាងជំទាស់មិនព្រមរៀបការតាមការរៀបចំពីចាស់ទុំនៅអាយុ

១៤ ឆ្នាំ ឪពុកម្ដាយរបស់នាងបានបន្ទោសក្រុមជំនុំក្នុងការដែលពួកគេបាត់បង់ប្រាក់បណ្ណាការរបស់នាង ព្រមទាំងចាប់ផ្ដើមតិះដៀលក្រុមជំនុំនៅជុំវិញភូមិទាំងមូលផង។

រីឯគ្រូគង្វាលជាប្ដីប្រពន្ធមួយគូដែលបានផ្លាស់ទៅរស់នៅទីនោះពីស្រុកឆ្ងាយដើម្បីដាំក្រុមជំនុំ បានធ្វើយ៉ាងណាជួយថែទាំនាង និងជួយឲ្យនាងអាចបន្តទៅរៀននៅសាលាបាន។ នាងបន្តថា «ខ្ញុំមិនបានដឹងថា តើខ្ញុំខកខានអ្វីខ្លះទេ។ ពីមុនខ្ញុំដូចជាកង្កែបក្នុងអណ្ដូងអញ្ចឹង។»

បើយោងតាមរឿងព្រេងប្រពៃណីខ្មែរ កង្កែបនៅក្នុងអណ្ដូងអាចងើយមើលទៅលើ ហើយឃើញផ្ទៃមេឃ ប៉ុន្តែវាមិនអាចស្រមៃពីពិភពលោកដែលនៅក្រៅអណ្ដូងបានទេ លុះត្រាតែវាអាចចេញផុតពីអណ្ដូងសិន។

នៅឯមហាសន្និបាតគ្រិស្តបរិស័ទអាស៊ី មានយុវសិស្សរាប់ពាន់នាក់ជួបជុំគ្នាជុំវិញឆាក ដើម្បីទទួលការអធិស្ឋានសម្រាប់ការងាររបស់ពួកគេនាពេលអនាគត ឬក្រុមគ្រួសាររបស់ពួកគេក្នុងការទទួលជឿលើព្រះគ្រិស្ត បរិយាកាសនៃការផុសផុលកំពុងតែកើតឡើងយ៉ាងខ្លាំងក្លានៅទូទាំងប្រទេសកម្ពុជា។

លោកសុភា ដែលមកពីក្រុមជំនុំជីវិតថ្មីមានប្រសាសន៍ថា «នេះជាប្រទេសជាតិមួយដែលត្រូវការសេចក្ដីសង្ឃឹមថ្មី។ ពួកគេចង់ឃើញអ្វីម្យ៉ាងដែលពិតប្រាកដ។ វាជាឱកាសដែលក្រុមជំនុំរបស់ព្រះយេស៊ូអាចប្រែជាពិតជាក់ស្ដែងដល់ពួកគេ។

គ្រូគង្វាលរូបនេះបន្តថា «មានភាពបន្ទាន់ដ៏ធំសម្បើមសម្រាប់ប្រទេសកម្ពុជា។ មានបង្អួចបើកចំហ ហើយខ្ញុំមិនប្រាកដថា តើបង្អួចនោះនឹងបើកចំហដល់ពេលណាទេ»។